# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ៣៦ ក្រ៦ "ស"

-ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ ២២៧៧

ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២

-សំណុំរឿងស៊ើបសួរលេខ ១៧៩៤

ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២

-សំណុំរឿងជំនុំជម្រះលេខ ៣៦៩៩

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ

កាលបរិច្ឆេទបើកសវនាការ ៖ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង៨ ព្រឹក

កាលបរិច្ឆេទប្រកាសសាលក្រម៖ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង៨ និង ៣០ នាទីព្រឹក

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ជាចៅក្រមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

លោកស្រី [redacted] ជាចៅក្រមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ២២៧៧ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ដែលមាន**ជនជាប់ចោទ៖**

១-ឈ្មោះ[redacted] **ប៊ុនកុមារ** ហៅ**ខ្ទួច** ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តព្រៃវែង មានទីលំនៅមុនឃាត់ខ្លួននៅស្នាក់នៅបន្ទប់ជួល ផ្លូវបេតុង ភូមិក្រុងថ្មី សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] **សាវ៉ាយ** (រស់) ម្តាយឈ្មោះ[redacted] **ប៊ុនធឿន** (រស់) ប្រពន្ធឈ្មោះ[redacted] **សុខឆេត** ទោសពីមុនគ្មាន ជានីតិជន ។

-តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៣៨៥២"ញ" ដ.ឃ.ដ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ។

មានលោកស្រី[redacted]ជាមេធាវីការពារក្តី ។

២-ឈ្មោះ[redacted] **សុភា** ហៅ**ភា** ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរជាងឈើ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តស្វាយរៀង មានទីលំនៅមុនឃាត់ខ្លួននៅស្នាក់នៅបន្ទប់ជួល ផ្លូវ២០០៤ ភូមិអូរបែកក្អម សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] **ព្រហស្បតិ៍** (រស់) ម្តាយឈ្មោះ[redacted] (រស់) នៅលីវ ទោសពីមុនគ្មាន ជានីតិជន ។

-តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៣៨៥៥"ញ" ដ.ឃ.ដ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ។

Scanned with CamScanner

មានលោក [redacted] ជាមេធាវីការពារក្តី ។

៣-ឈ្មោះ [redacted] ចំរើន ហៅឌីណា ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] ខេត្តពោធិ៍សាត់ មានទីលំនៅមុនឃាត់ខ្លួននៅស្នាក់នៅបន្ទប់ជួល ផ្លូវបេតុង ភូមិដំណាក់ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះយាន (រស់) ម្តាយឈ្មោះ [redacted] ចាន់ណា (រស់) នៅលីវ ទោសពីមុនគ្មាន ជានីតិជន ។

-តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៣៨៥៣"ញ" ដ.ឃ.ដ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ។

មានលោកស្រី [redacted] ជាមេធាវីការពារក្តី ។

៤-ឈ្មោះ [redacted] សៀងហៃ ហៅណាក់ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូ [redacted] ខេត្តកំពង់ចាម មានទីលំនៅមុនឃាត់ខ្លួននៅស្នាក់នៅបន្ទប់ជួល ផ្លូវបេតុង ភូមិដំណាក់ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] នី (ស្លាប់) ម្តាយឈ្មោះ [redacted] សឿន (រស់) នៅលីវ ទោសពីមុនគ្មាន ជានីតិជន ។

-តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៣៨៥៤"ញ" ដ.ឃ.ដ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ។

មានលោក [redacted] ជាមេធាវីការពារក្តី ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា និងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស** តាមមាត្រា៣៥៣ ,មាត្រា៣៥៧ និងមាត្រា២៤០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចវាលស្រែ ផ្លូវលំ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ ។

-ជនរងគ្រោះឈ្មោះ [redacted] វ៉ាងអ៊ី ភេទស្រី អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មការិនីរោងចក្រ មានអាសយដ្ឋាននៅបន្ទប់ជួល ផ្លូវបេតុង សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

-ជនរងគ្រោះឈ្មោះ [redacted] បុទុម ភេទស្រី អាយុ២៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មការិនីរោងចក្រ មានអាសយដ្ឋាននៅបន្ទប់ជួល ផ្លូវបេតុង សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង២២ និង៣០នាទី នៅចំណុចវាលស្រែ ផ្លូវលំ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានករណី **លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា និងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស** មួយកើតឡើងដែលបង្កឡើងដោយជនជាប់ចោទចំនួន៦នាក់ គឺឈ្មោះ [redacted] **ប៊ុនកុមារ** ហៅខ្មួច ,ឈ្មោះ [redacted] **សុភា** ហៅភា ,ឈ្មោះ [redacted] **ចំរើន** ហៅឌីណា ,ឈ្មោះ [redacted] **សៀងហៃ** ហៅណាក់ ,ឈ្មោះហ្វី និងឈ្មោះណាក់ ដោយមុនពេលកើតហេតុ ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនកុមារ** បានឆាតតាមហ្វេសប៊ុកហៅជនរងគ្រោះឈ្មោះ [redacted] **វ៉ាងអ៊ី** (ជាសង្សា) ដើរលេង ដោយឈ្មោះ [redacted] **ប៊ុនកុមារ** ជិះម៉ូតូ១គ្រឿងឌុបឈ្មោះ [redacted] **វ៉ាងអ៊ី** និងឈ្មោះ [redacted] **សុភា** ជិះម៉ូតូ១គ្រឿងទៀតជិះឌុបជនរងគ្រោះឈ្មោះ [redacted] **បុទុម** (ត្រូវជាមិត្តភក្តិរបស់ឈ្មោះ [redacted] **វ៉ាងអ៊ី**) ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនកុមារ** និងឈ្មោះ [redacted] **សុភា** បានឌុបជនរងគ្រោះទាំងពីរនាក់ចូលទៅផ្ទះសំណាក់នៅម្តុំឃ្លាំងរំសេវ តែជនរងគ្រោះឈ្មោះ [redacted] **វ៉ាងអ៊ី** ប្រកែកមិនព្រមចូល ទើបជនជាប់ចោទឈប់ម៉ូតូបន្តិច ស្របពេលនោះជនជាប់ចោទឈ្មោះ**ណាក់** បានឆាតតាមហ្វេសប៊ុកហៅឈ្មោះ [redacted] **ប៊ុនកុមារ** និងឈ្មោះ [redacted] **សុភា** ទៅចូលរួមខួបកំណើតនៅភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ



Scanned with CamScanner

ពេលនោះឈ្មោះ [redacted] **ប៊ុនកុមារ** និងឈ្មោះ [redacted] **សុភា** បើកម៉ូតូឌុបជនរងគ្រោះទាំងពីរនាក់ដល់ភូមិអន្លង់ក្ងាន ក៏ឃើញឈ្មោះ**ណាក់** និងឈ្មោះ**ហ៊ី** មកដល់រួចហៅឱ្យឈ្មោះ [redacted] **ប៊ុនកុមារ** និងឈ្មោះ [redacted] **សុភា** ឱ្យបើកម៉ូតូតាមពីក្រោយនាំគ្នាទីកន្លែងកើតហេតុពេលទៅដល់ឃើញមានឈ្មោះ [redacted] **ចំរើន** និងឈ្មោះ [redacted] **សៀងហៃ** កំពុងអង្គុយចាំនៅលើម៉ូតូ ពេលទៅដល់ជនរងគ្រោះបានសួរថា មកទីនេះធ្វើអី ភ្លាមនោះឈ្មោះ [redacted] **ប៊ុនកុមារ** ,ឈ្មោះ [redacted] **សុភា** ,ឈ្មោះ [redacted] **សៀងហៃ** , ឈ្មោះ [redacted] **ចំរើន** ,ឈ្មោះ**ណាក់** និងឈ្មោះ**ហ៊ី** បាននាំគ្នាធ្វើសកម្មភាពចាប់ក្រៀកដៃជនរងគ្រោះទាំងពីរជាប់ រួចនាំគ្នាដោះយកសម្ភារៈរួមមាន៖គ្រឿងអលង្ការ(ទូរស័ព្ទដៃម៉ាកស៊ាំសុង ពណ៌ខ្មៅចំនួន១គ្រឿង ,ខ្សែកប្លាទីនចំនួន១ខ្សែ,ចិញ្ចៀនប្លាទីនចំនួន១វង់ ជារបស់ជនរងគ្រោះឈ្មោះ [redacted] **វ៉ាងអី** និងទូរស័ព្ទដៃម៉ាកអាយហ្វូន១១ ពណ៌ត្រួយចេកចំនួន១គ្រឿង,ខ្សែកប្លាទីន១ខ្សែ និងប្រាក់រៀលចំនួន២០ម៉ឺនរៀល ជារបស់ជនរងគ្រោះឈ្មោះ [redacted] **បុទុម** ) និងបានចាប់ស្រាតខោអាវចេញពីដងខ្លួនរបស់ជនរងគ្រោះទាំងពីរអស់ហើយស្រែកគំរាមថា (នៅឱ្យស្ងៀមបើរើបំរ៉ាស់ពួកខ្លួននឹងកាត់ដៃកាត់ជើងចោល) រួចក្រុមជនជាប់ចោទបាននាំគ្នាធ្វើសកម្មភាពរំលោភបូកទៅលើជនរងគ្រោះឈ្មោះ [redacted] **វ៉ាងអី** និងឈ្មោះ [redacted] **បុទុម** បានសម្រេចម្តងម្នាក់ៗ បន្ទាប់មកក្រុមជនជាប់ចោទខាងលើក៏នាំគ្នាប្រមូលយកសម្ភារៈ និងគ្រឿងអលង្ការរួចនាំគ្នាជិះម៉ូតូគេចខ្លួនបាត់អស់ ។ ក្រោយពីកើតហេតុជនរងគ្រោះឈ្មោះ [redacted] **វ៉ាងអី** និងឈ្មោះ [redacted] **បុទុម** បាននាំគ្នាទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃ្មួញ ក្រោយពីទទួលបានពាក្យបណ្តឹងសមត្ថកិច្ចបានធ្វើការស្រាវជ្រាវ រហូតដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ ទើបឈានដល់ការឃាត់ខ្លួនឈ្មោះ [redacted] **ប៊ុនកុមារ** ,ឈ្មោះ [redacted] **សុភា** ,ឈ្មោះ [redacted] **ចំរើន** និងឈ្មោះ [redacted] **សៀងហៃ** និងបានដកហូតវត្ថុតាងម៉ូតូចំនួន៣គ្រឿង រួចនាំយកមកធ្វើការសាកសួរតែម្តង ។ ចំណែកឈ្មោះ**ណាក់** និងឈ្មោះ**ហ៊ី** បានរត់គេចខ្លួនបាត់ ។

**-បានឃើញ** របាយការណ៍សំយោគលេខ០៩០/២២ រ.ប.ក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ១៧៥២ អ.យ.ណ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ កំណត់ហេតុទទួលវត្ថុចាប់យកលេខ៨៨៧ រ.វ.ត ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូង និង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៣២៤៩ អ.យ.ណ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ របស់លោក [redacted] **ប៊ុនហេង** របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៤៨០៥ "ញ"ដ.ដ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] **ប៊ុនធឿន** ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនកុមារ** នៅបានឆ្លើយថា៖មុនពេលកើតហេតុខ្លួនស្គាល់ជនរងគ្រោះឈ្មោះ [redacted] **វ៉ាងអី** និងមិត្តភក្តិគាត់ម្នាក់ទៀតមិនស្គាល់ឈ្មោះតាមរយៈហ្វេសប៊ុក ។ នៅថ្ងៃកើតហេតុខ្លួនបានបបួលជនរងគ្រោះជិះម៉ូតូដើរលេង ហើយខ្លួនបានបបួលឈ្មោះ [redacted] **សុភា** ទៅជាមួយគ្នាដោយជិះម៉ូតូម្នាក់មួយដើម្បីទៅឌុបជនរងគ្រោះ ពេលទៅដល់ផ្ទះជនរងគ្រោះខ្លួនឌុបឈ្មោះ [redacted] **វ៉ាងអី** ចំណែកឈ្មោះ [redacted] **សុភា** ឌុបមិត្តភក្តិរបស់ឈ្មោះ [redacted] **វ៉ាងអី** បន្ទាប់មកពួកខ្លួនបាន

ទៅហូបមីហិលនៅម្តុំផ្សារបឹងឈូក ពេលហូបរួចពួកខ្លួនបានជិះម៉ូតូទៅផ្ទះសំណាក់នៅនៅម្តុំផ្សារហេងលី តែពេលទៅដល់ផ្ទះសំណាក់មិត្តភក្តិរបស់ឈ្មោះ[redacted] **រ៉ាងអី** មិនព្រមចូលទេ គឺគាត់ចង់ដើរលេងនៅត្រើយម្ខាងសិន ។ ពេលនោះដែរស្រាប់តែឈ្មោះ**ណាក់** បានអាតមកខ្លួនបបួលពួកខ្លួនទៅខួបកំណើតនៅឃ្លាំង ពេលពួកខ្លួនជិះជិតដល់ឃ្លាំងក៏ជួបឈ្មោះ**ណាក់** កំពុងទិញស្រា ហើយពួកខ្លួនក៏ជិះម៉ូតូតាមក្រោយឈ្មោះ**ណាក់** ពេលទៅដល់ដីវាលខ្លួនឃើញឈ្មោះ[redacted] **ចំរើន** , ឈ្មោះ[redacted] **សៀងហៃ** និងមិត្តភក្តិម្នាក់ទៀត ។ ពេលផឹកស្រារួច ខ្លួនបាននិយាយជាមួយឈ្មោះ[redacted] **រ៉ាងអី** ត្រូវរ៉ូវគ្នា ពួកគួចក៏ដើរទៅវាលស្រែដើម្បីដេកជាមួយគ្នា បន្ទាប់មកឈ្មោះ[redacted] **សៀងហៃ** បានដើរទៅដែរ ហើយនិយាយជាមួយឈ្មោះ[redacted] **រ៉ាងអី** ហើយពួកគេបានព្រមព្រៀងគ្នារួមរ័ក្ខបន្ត ។ ចំណែកឈ្មោះ[redacted] **សុភា** មិនបានប្រព្រឹត្តអ្វីទេ ហើយក៏មិនបានផលប្រយោជន៍អ្វីដែរ ។ ខ្លួនមិនបានដឹងថាអ្នកណាជាអ្នកដោះយកគ្រឿងអលង្ការរបស់ជនរងគ្រោះទេ ហើយពួកខ្លួនមិនបានគំរាមកំហែងលើជនរងគ្រោះឡើយ គឺជនរងគ្រោះបានព្រមព្រៀងដោយស្ម័គ្រចិត្ត ។

-ជនជាប់ចោទឈ្មោះ[redacted] **សុភា** បានឆ្លើយថា៖នៅថ្ងៃកើតហេតុឈ្មោះ[redacted] **ប៊ុនកុមារ** ហៅ**ខ្មួច** បានបបួលខ្លួនទៅចោមចៅដើម្បីទៅដឹកនារីរងគ្រោះដើម្បីទៅហូបមីហិលនៅបឹងឈូក ដោយឈ្មោះ**ខ្មួច** ដឹកសង្សារគាត់ ចំណែកខ្លួនដឹងមិត្តភក្តិសង្សារឈ្មោះ**ខ្មួច** បន្ទាប់ពីហូបមីហិលរួច ពួកខ្លួនបានដឹងនារីរងគ្រោះទាំងពីរនាក់ទៅផ្ទះសំណាក់នៅម្តុំផ្សារហេងលី ពេលទៅដល់ផ្ទះសំណាក់ជនរងគ្រោះមិនព្រម ហើយពេលនោះដែរឈ្មោះ**ណាក់** បានខលមកឈ្មោះ**ខ្មួច** បបួលទៅខួបកំណើត ពេលនោះខ្លួនបានសួរទៅជនរងគ្រោះថាអូនទៅអត់ គាត់ឆ្លើយថាទៅ ពេលទៅដល់កន្លែងខួបកំណើតខ្លួនឃើញមានគ្នាចំនួន៤នាក់ទៀត បន្ទាប់មកពួកខ្លួនបានហូបស្រាហើយ ខ្លួនឃើញឈ្មោះ**ណាក់** បានដើរមកជិតនារីរងគ្រោះដែលខ្លួនឌុបមក ពេលឃើញដូច្នេះខ្លួនក៏ដើរចេញទៅលេងទូរស័ព្ទ ព្រោះខ្លួនឃើញពួកគេថើបគ្នា បន្ទាប់មកខ្លួនឃើញនារីរងគ្រោះស្រាតខោហើយពួកគេក៏រួមរ័ក្ខគ្នា បន្ទាប់មកខ្លួនក៏ឃើញឈ្មោះ[redacted] **ចំរើន** និងឈ្មោះ**ហ៊ី** ចូលទៅរួមរ័ក្ខជាមួយនារីដែលខ្លួនឌុបដែរ ចំណែកឈ្មោះ**ខ្មួច** ខ្លួនឃើញដើរចេញទៅទីទួលជាមួយនារីម្នាក់ទៀតដើម្បីរួមរ័ក្ខគ្នា បន្ទាប់មកឃើញឈ្មោះ[redacted] **សៀងហៃ** ដើរទៅសុំរួមរ័ក្ខជាមួយនារីរងគ្រោះដែរ ។ ខ្លួនមិនបានដឹងថាអ្នកណាជាអ្នកដោះយកគ្រឿងអលង្ការរបស់ជនរងគ្រោះទេ ។ បន្ទាប់ពីកើតហេតុខ្លួនបានសួរទៅនារីរងគ្រោះថា ឱ្យខ្លួនជូនទៅផ្ទះអត់ ពេលនោះគាត់ឆ្លើយថាមិនបាច់ទេ ចាំគាត់ជិះPassapp ទៅខ្លួនឯង ពេលលឺដូច្នេះខ្លួនក៏ជិះម៉ូតូទៅផ្ទះសំរាក ។ លុះព្រឹកឡើងឈ្មោះ**ហ៊ី** បានទូរស័ព្ទទៅខ្លួនដើម្បីឱ្យយកទូរស័ព្ទ និងគ្រឿងអលង្ការទៅលក់ ពេលនោះខ្លួនបានសួរថា បានមកពីណា ឈ្មោះ**ហ៊ី** ឆ្លើយថា បានមកពីយប់មិញ បន្ទាប់ពីលក់បានលុយហើយ ខ្លួនបានប្រគល់លុយឱ្យទៅឈ្មោះ**ហ៊ី** ទាំងអស់ បន្ទាប់មកឈ្មោះ**ហ៊ី** បានដឹកខ្លួនទៅទុកចោលនៅហាងកាហ្វេ ។ ខ្លួនសូមបញ្ជាក់ជូនតុលាការថា នៅពេលកើតហេតុ ខ្លួនមិនបានឃើញឈ្មោះ[redacted] **ប៊ុនកុមារ** ,ឈ្មោះ[redacted] **ចំរើន** ,ឈ្មោះ[redacted] **សៀងហៃ** ,ឈ្មោះ**ណាក់** និងឈ្មោះ**ហ៊ី** បង្ខិតបង្ខំ រឺគំរាមកំហែងទៅលើជនរងគ្រោះទេ ហើយក៏មិនលឺស័លេងប្រកែកគ្នាដែរ ។ ទីតាំងកន្លែងកើតហេតុមានចំងាយពីផ្លូវប្រហែល ២០ម៉ែត្រ មានមនុស្សអ៊ូអរ បើជនរងគ្រោះស្រែកនឹងលឺដល់ប្រជាពលរដ្ឋដែលនៅក្បែរនោះ ។

-ជនជាប់ចោទឈ្មោះ[redacted] **សៀវហៃ** បានឆ្លើយថា៖នៅថ្ងៃកើតហេតុឈ្មោះ[redacted] **ចំរើន** បានខលមកឈ្មោះ**ណាក់** (តូច) ហើយខ្លួនបានទៅជាមួយឈ្មោះ**ណាក់** ទៅកន្លែងវាលស្រែ មានផ្ទះប្រជាពលរដ្ឋដែរ តែងងឹតបន្តិច ពេលឈ្មោះ**ណាក់** (ធំ) មកដល់គាត់ឱ្យខ្លួនទៅជិះម៉ូតូទៅទិញស្រាកន្លះកេស បន្ទាប់មកខ្លួនឃើញឈ្មោះ[redacted] **សុភា** ,ឈ្មោះ[redacted] **ប៊ុនកុមារ** និងនារីពីរនាក់ទៀត ។ នៅជុំវិញដីវាលនោះមិនមានគេលក់ដូរទេ បន្ទាប់ពីផឹករួច ខ្លួនក៏ឃើញឈ្មោះ[redacted]

**ប៊ុនកុមារ** និងនារីឈ្មោះ**វ៉ាងអ៊ី** រួមរ័ក្ខគ្នា បន្ទាប់មកខ្លួនក៏ដើរទៅសុំនារីរងគ្រោះរួមរ័ក្ខដែរហើយនារីនោះក៏យល់ព្រមដោយស្ម័គ្រចិត្ត បន្ទាប់ពីរួមរ័ក្ខរួចខ្លួនបានសួរទៅនារីនោះថា ឱ្យបងជូនទៅផ្ទះអត់ នាងបានឆ្លើយថាមិនបាច់ទេ ចាំនាងទៅដោយខ្លួនឯង ហើយខ្លួនក៏ជិះម៉ូតូទៅផ្ទះដេកទៅ ។ ខ្លួនមិនបានដោះយកគ្រឿងអលង្ការរបស់ជនរងគ្រោះទេ ចំណែកឈ្មោះ**សុភា** ខ្លួនឃើញគាត់ឈរលេងទូរស័ព្ទនៅលើផ្លូវ គាត់មិនបានរួមរ័ក្ខជាមួយនារីរងគ្រោះទេ ។ ចម្លើយនៅសមត្ថកិច្ចខ្លួនសុំទទួលស្គាល់ខ្លះ និងបដិសេធខ្លះ ។ ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាបានរំលោភលើជនរងគ្រោះ បន្ទាប់ពីឈ្មោះ[redacted] **ប៊ុនកុមារ** រំលោភរួចពិតមែន រីឯការដោះយកគ្រឿងពីជនរងគ្រោះខ្លួនមិនបានប្រព្រឹត្តឡើយ ។ ចំណែកជនរងគ្រោះឈ្មោះ[redacted] **បុទុម** ខ្លួនឃើញឈ្មោះ[redacted] **ចំរើន** ,ឈ្មោះ**ណាក់** និងឈ្មោះ**ហ៊ី** ចាប់រំលោភ ។ ខ្លួនមិនទទួលបានចំណែកពីការលក់គ្រឿងអលង្ការទេ ។

-ជនជាប់ចោទឈ្មោះ[redacted] **ចំរើន** បានឆ្លើយថា៖នៅថ្ងៃកើតហេតុឈ្មោះ**ណាក់** បានខលមកខ្លួនហៅទៅខួបកំណើត បន្ទាប់មកឈ្មោះ**ណាក់** បានជិះម៉ូតូមកយកខ្លួនមានគ្នា២នាក់ ជិះទៅដីឡូតិ៍នៅសែនសុខ ។ ពេលទៅដល់ដីឡូតិ៍ខ្លួនឃើញឈ្មោះ**ណាក់** និយាយជាមួយនារីម្នាក់ដែលឈ្មោះ[redacted] **សុភា** ឌុបមក បន្ទាប់មកខ្លួនឃើញពួកគេដេកជាមួយគ្នា ក្រោយមកឃើញឈ្មោះ**ហ៊ី** ទៅដេកជាមួយនារីនោះបន្ត បន្ទាប់មកទៀតខ្លួនបានចូលទៅដេកជាមួយនារីនោះដែរ តែមិនបានឱ្យលុយទៅនារីនោះទេ ។ ចំណែកឈ្មោះ[redacted] **ប៊ុនកុមារ** ខ្លួនឃើញគាត់ដេកជាមួយនារីដែលគាត់ដឹកមក បន្ទាប់មកឃើញឈ្មោះ[redacted] **សៀងហៃ** ទៅដេកជាមួយនារីនោះបន្តទៀត ។ ចំណែកឈ្មោះ[redacted] **សុភា** មិនបានរួមភេទជាមួយអ្នកណាទេ គឺវាវល់អង្គុយលេងទូរស័ព្ទ ។ នៅកន្លែងកើតហេតុគឺជាដីឡូតិ៍មិនមានផ្ទះរបស់ប្រជាពលរដ្ឋ តែបើនារីរងគ្រោះស្រែកអាចលឺដល់ប្រជាពលរដ្ឋ ព្រោះមានផ្លូវនៅជិតនោះប្រវែងប្រហែល២០ម៉ែត្រ មានមនុស្សទៅមកជាច្រើន ។ នៅកន្លែងកើតហេតុពួកខ្លួនមិនបានផឹកស្រាទេ ។ ចំពោះចម្លើយនៅសមត្ថកិច្ចខ្លួនសូមបដិសេធចោលព្រោះសមត្ថកិច្ចបានវាយខ្លួនឱ្យឆ្លើយ តែខ្លួនសូមទទួលស្គាល់ថា ខ្លួនពិតជាបានរំលោភសេពសន្ថវៈលើជនរងគ្រោះមែន ចំណែកឈ្មោះ[redacted] **សុភា** មិនរួមភេទជាមួយអ្នកណាទេ គឺវាវល់អង្គុយលេងទូរស័ព្ទ ។

-ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះឈ្មោះ[redacted] **វ៉ាងអ៊ី** បានឆ្លើយនៅសមត្ថកិច្ចថា៖មុនពេលកើតហេតុនៅដើមខែមេសា ឆ្នាំ២០២២ ខ្លួនបានស្គាល់ឈ្មោះ[redacted] **ប៊ុនកុមារ** (តាមគណនីហ្វេសប៊ុក Sau Zin ) តាមរយៈហ្វេសប៊ុក ហើយបានរាប់អានដើរលេងជាមួយគ្នា ។ នៅយប់ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ ឈ្មោះ[redacted] **ប៊ុនកុមារ** បានឆាតតាមហ្វេសប៊ុកហៅខ្លួន និងឈ្មោះ[redacted] **បុទុម** ស្នាក់នៅបន្ទប់ជួលជាមួយខ្លួនដើរលេង ខ្លួនក៏ឆាតតបតាមហ្វេសប៊ុកប្រាប់ទីតាំងបន្ទប់ជួល រួចខ្លួន និងឈ្មោះ[redacted] **បុទុម** បានដើរមកឈរចាំនៅមុខផ្លូវ មួយសន្ទុះក្រោយឃើញឈ្មោះ[redacted] **ប៊ុនកុមារ** បើកម៉ូតូ០១គ្រឿងម៉ាកសេ១២៥ ពណ៌ខ្មៅ និងឃើញមនុស្សប្រុសម្នាក់ជាមិត្តភក្តិរបស់ឈ្មោះ[redacted] **ប៊ុនកុមារ** បើកម៉ូតូម៉ាកសេ១២៥ មកដល់ រួចឈ្មោះ[redacted] **ប៊ុនកុមារ** ក៏បើកម៉ូតូឌុបខ្លួន និងមិត្តភក្តិរបស់ឈ្មោះ[redacted] **ប៊ុនកុមារ** បើកម៉ូតូឌុបឈ្មោះ[redacted] **បុទុម** ដើរលេងនិងស៊ីអីក្នុងរាជធានីភ្នំពេញ បន្ទាប់ពីស៊ីអីរួច ឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិបានបើកម៉ូតូឌុបខ្លួន និងឈ្មោះ[redacted] **បុទុម** ចូលផ្ទះសំណាក់ តែខ្លួនប្រកែកថាមិនចូលទេ ឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិក៏បើកម៉ូតូចេញ ដោយប្រាប់ថាទៅខួបកំណើតបង ពេលធ្វើដំណើរមកដល់ផ្លូវលំស្ងាត់ មានវាលស្រែ (សង្កាត់ឃ្មួញ) បានឈប់ម៉ូតូហើយខ្លួន ក៏ឃើញមនុស្សប្រុស៤នាក់ទៀត កំពុងអង្គុយលើម៉ូតូ២គ្រឿង នៅលើផ្លូវវាលស្រែ រួចខ្លួនក៏សួរឈ្មោះ[redacted] **ប៊ុនកុមារ** មកទីនេះធ្វើអីឈ្មោះ[redacted] **ប៊ុនកុមារ** តបថា "ចាំបង" បានបន្តិច ស្រាប់តែឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិចំនួន៥នាក់ ធ្វើសកម្មភាព



Scanned with CamScanner

ចាប់ក្រៀកដៃទាំងពីររបស់ខ្លួន និងឈ្មោះ[redacted] **បុទុម** ព័ទ្ធទៅក្រោយជាប់ រួចនាំគ្នាចាប់ស្រាតខោអាវ និងដោះគ្រឿងអលង្ការចេញពីខ្លួន និងឈ្មោះ[redacted] **បុទុម** អស់ ហើយឈ្មោះ[redacted]**ប៊ុនកុមារ** ចាប់ផ្ដើមធ្វើសកម្មភាពចាប់ផ្ដួលខ្លួន ទៅលើដីវាលស្រែ ដេកទ្រោប ខ្លួនរើបំរាស់ស្រាប់តែឈ្មោះ[redacted] **ប៊ុនកុមារ** បានយកដៃទះចំផ្ទៃមុខខ្លួន១ដៃ និងឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិ ហើយបាននិយាយគំរាមដាក់ខ្លួន និងឈ្មោះ[redacted] **បុទុម** ថា "បើរើបំរាស់ខ្លួនទៀត និងសម្លាប់ចោលទាំងពីរ" ឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិចំនួន៥នាក់ ក៏បន្តធ្វើសកម្មភាពចាប់រំលោភបូកលើខ្លួន និងឈ្មោះ[redacted]**បុទុម** បានសម្រេចម្ដងម្នាក់ៗ បន្ទាប់ពីធ្វើសកម្មភាពរួច ឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិ៥នាក់ បាននាំគ្នាឡើងជិះម៉ូតូ រួចបាននិយាយគំរាមខ្លួន និងឈ្មោះ[redacted] **បុទុម** ថា "បើនិយាយប្រាប់អ្នកណា និងសម្លាប់កាត់ដៃជើងចោល" ឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិ៥នាក់ក៏បើកម៉ូតូចេញទៅបាត់ទៅ ដោយប្រមូលយកគ្រឿងអលង្ការ (ទូរស័ព្ទម៉ាកសាំងសុង ពណ៌ខ្មៅ មានស៊ីមលេខ ០៩៦ ៩៨៩៣៩០៥ ,ខ្សែកប្លាទីនចំនួន១ខ្សែ ,ចិញ្ចៀនប្លាទីនចំនួន១វង់ (របស់ខ្លួន) ,ទូរស័ព្ទដៃម៉ាកអាហ្វូន១១ ពណ៌ត្រួយចេកមានស៊ីម ,ខ្សែប្លាទីន១ខ្សែ ,ប្រាក់២០ម៉ឺនរៀល (របស់ឈ្មោះ[redacted] **បុទុម**) បន្ទាប់មកខ្លួន និងឈ្មោះ[redacted] **បុទុម** ក៏នាំគ្នាស្លៀកពាក់ខោអាវរួចទៅដាក់ពាក្យបណ្ដឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃ្លាញ ឱ្យសមត្ថកិច្ចជួយស្រាវជ្រាវរកឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិ មកអនុវត្តតាមច្បាប់ ។ នៅយប់ថ្ងៃទី០៨ ខែឧសភា ខ្លួន និងឈ្មោះ[redacted] **បុទុម** កំពុងនៅបន្ទប់ជួល បានទទួលពត៌មានពីសមត្ថកិច្ច ឃាត់បានឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិ(ដែលបានធ្វើសកម្មភាពចាប់រំលោភបូកលើខ្លួន និងឈ្មោះ[redacted]**បុទុម** ) សមត្ថកិច្ចបានហៅខ្លួន និងឈ្មោះ[redacted] **បុទុម** មកអធិការដ្ឋាននគរបាលខណ្ឌសែនសុខ បង្ហាញមុខឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិដើម្បីសាកសួរខ្លួនបន្ថែម ។ សំណូមពរសុំទាមទារសំណងចំនួន៨លានរៀល និងសុំឱ្យផ្ដន្ទាទោសជនល្មើសតាមផ្លូវច្បាប់ ។

-ជនរងគ្រោះឈ្មោះ[redacted]**បុទុម** បានឆ្លើយនៅសមត្ថកិច្ចថា៖ នៅយប់ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ ឈ្មោះ[redacted] **ប៊ុនកុមារ** (ឈ្មោះគណនីហ្វេសប៊ុកSau Zin )ដែលឈ្មោះ[redacted]**វ៉ាំងអី** ស្នាក់នៅបន្ទប់ជាមួយគ្នា បានស្គាល់គ្នាឆាតតាមហ្វេសប៊ុកឆាតមកឈ្មោះ[redacted] **វ៉ាំងអី** ហៅដើរលេងឈ្មោះ[redacted]**វ៉ាំងអី** ក៏ឆាតតាមតាមហ្វេសប៊ុក ប្រាប់ទីតាំងបន្ទប់ជួល រួចខ្លួន និងឈ្មោះ[redacted] **វ៉ាំងអី** បានដើរមកឈរចាំនៅមុខផ្លូវ មួយសន្ទុះក្រោយមកក៏ឃើញឈ្មោះ[redacted] **ប៊ុនកុមារ** បើកម៉ូតូ១គ្រឿងម៉ាកសេ១២៥ ពណ៌ខ្មៅ និងឃើញមនុស្សប្រុសម្នាក់ជាមិត្តភក្តិរបស់ឈ្មោះ**ឈួន ប៊ុនកុមារ** បើកម៉ូតូ១គ្រឿងទៀតមកដល់ រួចឈ្មោះ[redacted] **ប៊ុនកុមារ** ក៏បើកម៉ូតូឌុបឈ្មោះ[redacted] **វ៉ាំងអី** និងមិត្តភក្តិរបស់ឈ្មោះ[redacted]**ប៊ុនកុមារ** បើកម៉ូតូឌុបខ្លួន ដើរលេងនិងស៊ីអីក្នុងរាជធានីភ្នំពេញ បន្ទាប់ពីស៊ីអីរួចឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិបានបើកម៉ូតូឌុបខ្លួន និងឈ្មោះ[redacted] **វ៉ាំងអី** ចូលផ្ទះសំណាក់ តែខ្លួន និងឈ្មោះ[redacted] **វ៉ាំងអី** ប្រកែកថាមិនចូលទេ ឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិក៏បើកម៉ូតូចេញ ដោយប្រាប់ទៅខួបកំណើតបង ពេលធ្វើដំណើរមកដល់ផ្លូវស្ងាត់ មានវាលស្រែ (សង្កាត់ឃ្លាញ) បានឈប់ម៉ូតូ ហើយខ្លួនក៏ឃើញមនុស្សប្រុស៤នាក់ទៀត កំពុងអង្គុយលើម៉ូតូ២គ្រឿងនៅលើផ្លូវវាលស្រែ រួចឈ្មោះ[redacted] **វ៉ាំងអី** ក៏សួរឈ្មោះ[redacted]**ប៊ុនកុមារ** មកទីនេះធ្វើអីឈ្មោះ[redacted] **ប៊ុនកុមារ** តបថា "ចាំបង" បានបន្តិច ស្រាប់តែឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិចំនួន៥នាក់ធ្វើសកម្មភាពចាប់ក្រៀកដៃទាំងពីរខ្លួន និងឈ្មោះ[redacted] **វ៉ាំងអី** ព័ទ្ធទៅក្រោយជាប់ រួចនាំគ្នាចាប់ស្រាតខោអាវ និងដោះគ្រឿងអលង្ការចេញពីដងខ្លួនពួកខ្លួនអស់ បន្ទាប់មកឈ្មោះ[redacted] **ប៊ុនកុមារ** ផ្ដើមធ្វើសកម្មភាពចាប់ផ្ដួលខ្លួន និងឈ្មោះ[redacted] **វ៉ាំងអី** ទៅលើដីវាលស្រែ ដេកទ្រោប ពេលនោះខ្លួនរើបំរាស់ ស្រាប់តែឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិបាននិយាយគំរាមដាក់ពួកខ្លួនថា "បើរើបំរាស់ខ្លួនទៀត និងសម្លាប់ចោលទាំងពីរ" ឈ្មោះ[redacted] **ប៊ុនកុមារ** និងមិត្តភក្តិ៥នាក់ក៏បន្តធ្វើសកម្មភាព



Scanned with CamScanner

ចាប់រំលោភឬកលើពួកខ្លួនបានសម្រេចម្តងម្នាក់ៗ បន្ទាប់ពីធ្វើសកម្មភាពរួច ឈ្មោះ[redacted] ប៊ុនកុមារ និងមិត្តភក្តិ៥នាក់បាននាំគ្នាឡើងជិះម៉ូតូ រួចបាននិយាយគំរាមពួកខ្លួនថា "បើនិយាយប្រាប់អ្នកណា និងសម្លាប់កាត់ដៃជើងចោល" ឈ្មោះ[redacted] ប៊ុនកុមារ និងមិត្តភក្តិ៥នាក់ ក៏បើកម៉ូតូចេញទៅបាត់ទៅ ដោយប្រមូលយកគ្រឿងអលង្ការមាន (ទូរស័ព្ទម៉ាកស៊ាំងសុងពណ៌ខ្មៅ មានស៊ីមលេខ ០៩៦ ៨៨៩៣៩០៥ ,ខ្សែកប្លាទីនចំនួន១ខ្សែ ,ចិញ្ចៀនប្លាទីនចំនួន១វង់(របស់ឈ្មោះថា វ៉ាងអ៊ី) , ទូរស័ព្ទដៃម៉ាករាហ្វ៊ូ១១ ពណ៌ត្រួយចេកមានស៊ីម ,ខ្សែប្លាទីន១ខ្សែ ,ប្រាក់២០ម៉ឺនរៀល(របស់ខ្លួន) បន្ទាប់មកពួកខ្លួនបាននាំគ្នាស្លៀកពាក់ខោអាវ រួចទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃ្មួញ ឲ្យសមត្ថកិច្ចជួយស្រាវជ្រាវរកឈ្មោះ[redacted] ប៊ុនកុមារ និងមិត្តភក្តិមកអនុវត្តតាមច្បាប់ ។ នៅយប់ថ្ងៃទី០៨ ខែឧសភា ខ្លួន និងឈ្មោះ[redacted] វ៉ាងអ៊ី កំពុងនៅបន្ទប់ជួល បានទទួលពត៌មានពីសមត្ថកិច្ច ឃាត់ខ្លួនបានឈ្មោះ[redacted] ប៊ុនកុមារ និងមិត្តភក្តិ ហើយសមត្ថកិច្ចបានហៅខ្លួន និងឈ្មោះ[redacted] វ៉ាងអ៊ី មកអធិការដ្ឋាននគរបាលខណ្ឌសែនសុខ បង្ហាញមុខឈ្មោះ[redacted] ប៊ុនកុមារ និងមិត្តភក្តិដើម្បីសាកសួរពួកខ្លួនបន្ថែម ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានពិនិត្យលើពាក្យបណ្តឹងរបស់ជនរងគ្រោះ របាយការណ៍របស់សមត្ថកិច្ច ចំលើយសារភាពរបស់ជនជាប់ចោទឃើញថា កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង២២ និង៣០នាទី នៅចំណុចវាលស្រែ ផ្លូវលំ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ពិតជាមានបទល្មើសលួចមានស្ថានទម្ងន់ និងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស ពិតមែន ចំណែកឈ្មោះ[redacted] សុភា មិនបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើជនរងគ្រោះទេ ដូច្នេះស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ៣២៥៩ អ.យ.ឍ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ទុកជាបានការដដែល ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឲ្យជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ[redacted] សុភា បានធ្វើសេចក្តីសន្និដ្ឋានថា៖តាមអង្គហេតុ និងចម្លើយសារភាពរបស់ជនជាប់ចោទទាំងបីនាក់បានឆ្លើយប្រហាក់ប្រហែលគ្នាថា ពួកគេពិតជាបានរួមភេទជាមួយជនរងគ្រោះពិតមែន ប៉ុន្តែកូនក្តីរបស់ខ្លួនឈ្មោះ[redacted] សុភា មិនបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើជនរងគ្រោះ រឺឈរមើលផ្លូវឲ្យជនជាប់ចោទផ្សេងទៀតឡើយ ហើយជនជនជាប់ចោទទាំងបីនាក់ក៏បានឆ្លើយអះអាងថាកូនក្តីខ្លួនមិនបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើជនរងគ្រោះឡើយ ដូច្នេះស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទតាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។

លោកស្រី[redacted] ចាន់ចរិយា ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ[redacted] ប៊ុនកុមារ ,ឈ្មោះ[redacted] ចំរើន និង ឈ្មោះ[redacted] សៀងហៃ បានធ្វើសេចក្តីសន្និដ្ឋានថា៖ខ្លួនយល់ស្របតាមសេចក្តីសន្និដ្ឋានរបស់សហភាគី តែសូមបញ្ជាក់បន្ថែមថា កូនក្តីខ្លួនមិនបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើជនរងគ្រោះទេ គឺកូនក្តីខ្លួនរួមភេទជាមួយជនរងគ្រោះដោយស្ម័គ្រចិត្ត ដូច្នេះស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ ។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ[illegible] ប៊ុនកុមារ បាននិយាយសម្តីចុងក្រោយបង្កួសថា៖ សុំឲ្យបន្ធូរបន្ថយទោសឲ្យខ្លួនផង ។

ជនជាប់ចោទឈ្មោះ[redacted] សុភា បាននិយាយសម្តីចុងក្រោយបង្កួសថា៖សុំឲ្យបន្ធូរបន្ថយទោសឲ្យខ្លួនផង ។

ជនជាប់ចោទឈ្មោះ [redacted] **ចំរើន** បាននិយាយសម្តីចុងក្រោយបង្អស់ថា៖សុំឱ្យបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

ជនជាប់ចោទឈ្មោះ [redacted] **សៀងហៃ** បាននិយាយសម្តីចុងក្រោយបង្អស់ថា៖សុំឱ្យបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សំអាងហេតុ</u>**

១-យោងតាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ និង ផ្អែកតាមការសាកសួរដេញដោលនាពេលសវនាការកំណត់បានថា កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ មានអំពើ **លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា និងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា**៣៥៣** ,មាត្រា**៣៥៧** និងមាត្រា**២៤០** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចវាលស្រែ ផ្លូវលំ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ បង្កឡើងដោយឈ្មោះ [redacted] **ប៊ុនកុមារ** ,ឈ្មោះ [redacted] **សុភា** ,ឈ្មោះ [redacted] **ចំរើន** និងឈ្មោះ [redacted] **សៀងហៃ** ពិតប្រាកដមែន ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនកុមារ** ,ឈ្មោះ [redacted] **ចំរើន** និងឈ្មោះ [redacted] **សៀងហៃ** បានឆ្លើយសារភាពថា៖ពួកខ្លួនពិតជាបានរំលោភសេពសន្ថវៈលើជនរងគ្រោះមែន តែមិនបានលួចយកគ្រឿងអលង្ការ និងទូរស័ព្ទរបស់ជនរងគ្រោះឡើយ ។ ការឆ្លើយដោះសារថាមិនបានយកគ្រឿងអលង្ការរបស់ជនរងគ្រោះនោះមិនមានភស្តុតាងណាបញ្ជាក់ឱ្យតុលាការជឿបានឡើយ ម្យ៉ាងទៀតចម្លើយសារភាពរបស់ជនជាប់ចោទទាំងអស់នៅសមត្ថកិច្ចបានឆ្លើយសារភាពថា ពិតជាបានដោះយកគ្រឿងអលង្ការរបស់ជនរងគ្រោះពិតមែន ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុភា** បានឆ្លើយបដិសេធថា៖ ខ្លួនមិនបានរំលោភសេពសន្ថវៈលើជនរងគ្រោះទេ តែផ្អែកតាមចម្លើយរបស់ជនរងគ្រោះបានឆ្លើយថា ជនជាប់ចោទទាំងអស់ពិតជាបានរំលោភសេពសន្ថវៈលើពួកនាងទាំងអស់គ្នាម្តងម្នាក់ៗពិតមែន ។

៤-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនកុមារ** ,ឈ្មោះ [redacted] **សុភា** ,ឈ្មោះ [redacted] **ចំរើន** និងឈ្មោះ [redacted] **សៀងហៃ** បានធ្វើសកម្មភាពរំលោភប្លន់ទៅលើជនរងគ្រោះ និងបានដកហូតទ្រព្យសម្បត្តិជនរងគ្រោះដោយចេតនា ដែលធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់សង្គមយ៉ាងធ្ងន់ធ្ងរ គឺមានធាតុផ្សំជាបទល្មើស **លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា និងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា**៣៥៣** ,មាត្រា**៣៥៧** និងមាត្រា**២៤០** នៃក្រមព្រហ្មទណ្ឌ។

៥-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនកុមារ** ,ឈ្មោះ [redacted] **សុភា** ,ឈ្មោះ [redacted] **ចំរើន** និងឈ្មោះ [redacted] **សៀងហៃ** ជានីតិជនដែលមានសមត្ថភាព និងស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើផ្ទាល់ខ្លួននៅពេលប្រព្រឹត្តបទល្មើស ។

៦-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលហេតុ និង មូលដ្ឋានគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនកុមារ** ,ឈ្មោះ [redacted] **សុភា** ,ឈ្មោះ [redacted] **ចំរើន** និងឈ្មោះ [redacted] **សៀងហៃ** ពីបទ **លួចមានស្ថានទម្ងន់**



Scanned with CamScanner

**ទោសដោយការប្រព្រឹត្តអំពើហិង្សា និងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា**៣៥៣** ,មាត្រា**៣៥៧** និងមាត្រា**២៤០** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចវាលស្រែ ផ្លូវលំ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ ។

៧-នៅក្នុងរឿងនេះជនរងគ្រោះឈ្មោះ[redacted] **វ៉ាំងអី** និងឈ្មោះ[redacted] **បុទុម** ទាមទារសំណងជម្ងឺចិត្ត និងបាត់បង់ទ្រព្យសម្បត្តិក្នុងម្នាក់ ១ចំនួន**៨.០០០.០០០៛ (ប្រាំបីលានរៀល)** ពីជនជាប់ចោទទាំង៤នាក់ ។

៨-វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៨៨៧ រ.វ.ត ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន៖-ម៉ូតូម៉ាកសេ ១២៥ ពណ៌ខ្មៅ ផ្លាកលេខ បន្ទាយមានជ័យ 1P-5783 ចំនួន១គ្រឿង (មិនប្រក្រតី) ,ម៉ូតូម៉ាកសេ១២៥ ពណ៌ក្រហម ផ្លាកលេខ ភ្នំពេញ 1GB-8809 ចំនួន១គ្រឿង (មិនប្រក្រតី) និងម៉ូតូម៉ាកប៊ីត ពណ៌ខៀវ ផ្លាកលេខ ភ្នំពេញ 1HW-8344 ចំនួន១គ្រឿង (មិនប្រក្រតី) គប្បីប្រគល់ឱ្យម្ចាស់ដើមវិញ ។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] **ប៊ុនកុមារ** ,ឈ្មោះ[redacted] **សុភា** ,ឈ្មោះ[redacted] **ចំរើន** និងឈ្មោះ[redacted] **សៀងហៃ** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា និងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា**៣៥៣** ,មាត្រា**៣៥៧** និងមាត្រា**២៤០** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចវាលស្រែ ផ្លូវលំ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើ

ក-ឈ្មោះ[redacted] **ប៊ុនកុមារ** ហៅ**ខ្ទូច** ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ

ខ-ឈ្មោះ[redacted] **សុភា** ហៅ**ភា** ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ

គ-ឈ្មោះ[redacted] **ចំរើន** ហៅ **ឌីណា** ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ

ឃ-ឈ្មោះ[redacted] **សៀងហៃ** ហៅ**ណាក់** ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ

សម្រេចដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន **១០ (ដប់) ឆ្នាំ** ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា**៣៥៣** ,មាត្រា**៣៥៧** និងមាត្រា**២៤០** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចវាលស្រែ ផ្លូវលំ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ ។

**២**-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted] **ប៊ុនកុមារ** ,ឈ្មោះ[redacted] **សុភា** ,ឈ្មោះ[redacted] **ចំរើន** និងឈ្មោះ[redacted] **សៀងហៃ** រួមគ្នាសងសំណងចំនួន**៨.០០០.០០០៛** (ប្រាំបីលាន) រៀល ឱ្យទៅជនរងគ្រោះឈ្មោះ[redacted] **បុទុម** និងសងសំណងចំនួន **៨.០០០.០០០៛** (ប្រាំបីលាន)រៀល ឱ្យទៅជនរងគ្រោះឈ្មោះ[redacted] **វ៉ាំងអី** ។

**៣**-វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៨៨៧ រ.វ.ត ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ៖



Scanned with CamScanner

-ម៉ូតូម៉ាកសេ ១២៥ ពណ៌ខ្មៅ ផ្លាកលេខ បន្ទាយមានជ័យ 1P-5783 ចំនួន១គ្រឿង (មិនប្រក្រតី)

-ម៉ូតូម៉ាកសេ ១២៥ ពណ៌ក្រហម ផ្លាកលេខ ភ្នំពេញ 1GB-8809 ចំនួន១គ្រឿង (មិនប្រក្រតី)

-ម៉ូតូម៉ាកប៊ីត ពណ៌ខៀវ ផ្លាកលេខ ភ្នំពេញ 1HW-8344 ចំនួន១គ្រឿង (មិនប្រក្រតី)

សម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ។

ជនជាប់ចោទមានសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|---|

ហត្ថលេខា និងត្រា [redacted]

..........................................................................................

**(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)**

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

[redacted]



Scanned with CamScanner